**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

&Fauna & Flora Saving Nature Together

BCOMING Biodiversity Conservation to Mitigate the risks of emerging infectious diseases

Funded by the European Union

## សេចក្តីប្រកាសព័ត៌មានរួម

## ការចេញផ្សាយរបាយការណ៍ស្តីពីការសិក្សាជីវៈចម្រុះនៅតំបន់ភ្នំថ្មកំបោរ ដែលបានរកឃើញប្រភេទថ្មី និងកម្រជាច្រើន

របាយការណ៍ស្តីពីការសិក្សាជីវៈចម្រុះនៅតំបន់ភ្នំថ្មកំបោរ ដែលបានបោះពុម្ពផ្សាយនៅថ្ងៃនេះ បានបង្ហាញពីប្រភេទសត្វជាច្រើនដែលរស់នៅក្នុងតំបន់ភ្នំថ្មកំបោរនៅក្នុងប្រទេសកម្ពុជា។ តាមរយៈការសិក្សារូងភ្នំជាង៦០នៅតាមតំបន់ភ្នំចំនួន១០ នៅខេត្តបាត់ដំបងនៃប្រទេសកម្ពុជា ការសិក្សាស្រាវជ្រាវនេះបានរកឃើញសត្វដែលគួរឱ្យចាប់អារម្មណ៍ជាច្រើនដែលមួយចំនួនធំគឺមានតែនៅក្នុងតំបន់ជាក់លាក់នេះប៉ុណ្ណោះ។

ដឹកនាំដោយអង្គការសត្វព្រៃ និងរុក្ខជាតិ សហការជាមួយក្រសួងបរិស្ថាន និងអ្នកជំនាញប្រព័ន្ធចំណែកថ្នាក់ យើងបានរកឃើញសត្វជាច្រើនដែលជាប្រភេទថ្មីសម្រាប់វិទ្យាសាស្រ្ត ដោយក្នុងនោះមាន តុកកែថ្មីចំនួន ៣ ប្រភេទ ដូចជា តុកកែភ្នំកំពីងពួយ(*Cyrtodactylus kampingpoiensis*) ជីងចក់ភ្នំខ្ពស់ (*Hemiphyllodactylus khpoh*) និង ជីងចក់ស្លឹកបាត់ដំបង(*Dixonius noctivagus*) ប្រភេទខ្យង២ ប្រភេទ ខ្យងឧទយាទិត្យ (*Clostophis udayaditinus*) និង ខ្យង *Chamalycaeus aduncus*) ប្រភេទម្រើមព្រះ ២ ប្រភេទ (Orthomorpha efefai) និង *Orthomorpha battambangiensis*) ដែលប្រភេទថ្មីទាំង ៧ នេះត្រូវបានបោះពុម្ពផ្សាយជាសាធារណៈ ខណៈដែលតុកកែថ្មីចំនួន ៣ ប្រភេទទៀត (*Gehyra* **sp. nov.**) (*Cyrtodactylus* **sp. nov.** ) និង (*Dixonius* **sp. nov.**) និងប្រភេទពស់ pit viper (*Trimeresurus* **sp. nov.**) កំពុងត្រូវបានកំណត់អត្តសញ្ញាណ។

ការស្រាវជ្រាវនេះ ក៏បានកត់ត្រានូវវត្តមាននៃប្រភេទសត្វដែលរងការគំរាមកំហែងជាសកលជាច្រើនប្រភេទ រួមមាន៖ សត្វពង្រូល ស្វាព្រាម ស្វាក្តាម ស្វាត្រោស ក្ងោក និងសត្វកែះជាដើម ដែលបង្ហាញពីតម្រូវការបន្ទាន់ក្នុងការការពារជម្រកទាំងនេះ។

តំបន់ទេសភាពភ្នំថ្មកំបោរគឺជាការបណ្តុំចូលគ្នានៃភ្នំថ្មកំបោរ និងរូងភ្នំ ដែលបង្កើតបានជាលក្ខណៈពិសេសៗដូចជារណ្តៅទឹក ប្រភពទឹក និងអូរក្រោមដីជាដើម។ ទោះបីជាការស្រាវជ្រាវនៅតំបន់នេះនៅមានកម្រិតនៅឡើយ តែតំបន់ភ្នំថ្មកំបោរគឺជាជម្រកដ៏សំខាន់បំផុតមួយនៅលើផែនដី ដែលសំបូរទៅដោយជីវៈចម្រុះដ៏ពិសេសៗមានវត្តមានតែនៅក្នុងតំបន់ជាក់លាក់ណាមួយប៉ុណ្ណោះ ។ តំបន់ទេសភាពទាំងនេះក៏មានសារៈសំខាន់ខាងផ្នែកវប្បធម៌ និងសាសនាចំពោះសហគមន៍មូលដ្ឋាន ហើយត្រូវបានគេឱ្យតម្លៃកាន់តែខ្លាំងឡើងៗសម្រាប់អេកូទេសចរណ៍ផងដែរ។

តំបន់ទេសភាពភ្នំថ្មកំបោរ កំពុងប្រឈមនឹងការគំរាមកំហែងកាន់តែខ្លាំងឡើងពីការជីកយករ៉ែ ការគ្រប់គ្រងសកម្មភាពទេសចរណ៍មិនត្រឹមត្រូវ ភ្លើងឆេះព្រៃ ការកាប់ព្រៃឈើ និងការបរបាញ់សត្វព្រៃខុសច្បាប់ជាដើម។

**ឯកឧត្តម ខ្វៃ អាទិត្យា អនុរដ្ឋលេខាធិការ និងជាអ្នកនាំពាក្យនៃក្រសួងបរិស្ថាន** មានប្រសាសន៍ថា៖ ការសិក្សាស្រាវជ្រាវដ៏មានសារៈសំខាន់នេះបង្ហាញជាថ្មីម្តងទៀតថា កម្ពុជាគឺជាប្រទេសដែលមានភាពសម្បូរបែបនៃធនធានធម្មជាតិ និងជីវជម្រុះដែលមានតម្លៃទាំងនៅក្នុងស្រុក និងសម្រាប់សកលលោក។ ប្រព័ន្ធអេកូឡូស៊ីរបស់យើង មិនត្រឹមតែជាទីជម្រកនៃប្រភេទសត្វកម្រ និងប្រភេទថ្មីៗសម្រាប់ពិភពលោកប៉ុណ្ណោះទេ ប៉ុន្តែវាក៏ផ្តល់នូវតម្លៃផ្នែកវប្បធម៌ ប្រពៃណី និងសេដ្ឋកិច្ចដល់សហគមន៍មូលដ្ឋានផងដែរ។ រាជរដ្ឋាភិបាលកម្ពុជា តាមរយៈក្រសួងបរិស្ថាន បានប្តេជ្ញាចិត្តយ៉ាងមុតមាំក្នុងការពង្រឹងការការពារ និងការគ្រប់គ្រងធនធានទាំងនោះប្រកបដោយនិរន្តរភាព។ យើងនឹងបន្តធ្វើការយ៉ាងជិតស្និទ្ធជាមួយដៃគូរបស់យើង ដើម្បីធានាថាការអភិវឌ្ឍន៍មានតុល្យភាពជាមួយនឹងការអភិរក្ស ជាលទ្ធផលបេតិកភណ្ឌធម្មជាតិរបស់យើងត្រូវបានការពារសម្រាប់មនុស្សជំនាន់ក្រោយ។

**កញ្ញា ធី សុធារីន មន្ត្រីសម្របសម្រួលផ្នែកជីវៈចម្រុះគម្រោងតំបន់ទេសភាពភ្នំថ្មកំបោរ** បានរៀបរាប់ថា៖ តំបន់ទេសភាពភ្នំថ្មកំបោរនៅក្នុងប្រទេសកម្ពុជាគឺជាកំណប់ដ៏អាថ៌កំបាំងនៃវិទ្យាសាស្ត្រដែលកំពុងរង់ចាំការស្រាវជ្រាវ។ ក្រៅពីនៅអាចមានវត្តមានប្រភេទល្មូន និងខ្យងដែលយើងមិនទាន់រកឃើញ ឬក៏រូងភ្នំដែលលាក់បាំងខ្លួន ក៏អាចនៅមានអ្វីៗជាច្រើនណាស់ដែលយើងមិនដឹងអំពីប្រព័ន្ធអេកូឡូស៊ីដ៏ពិសេសនេះ និងប្រភេទជីវៈចម្រុះដែលរស់នៅក្នុងតំបន់នោះ។ បើគ្មានការគ្រប់គ្រងប្រកបដោយចីរភាពទេ យើងប្រហែលជាបាត់បង់ឱកាសរកឃើញនូវអ្វីៗដ៏ពិសេសដែលមាននៅតំបន់ទាំងនេះ។ តំបន់ទេសភាពភ្នំថ្មកំបោរ កំពុងប្រឈមមុខនឹងបញ្ហាប្រឈមដែលកើតចេញពីកត្តាមនុស្ស ហើយប្រភេទជីវៈចម្រុះសំខាន់ៗក៏អាចផុតពូជមុនពេលវាត្រូវបានគេរកឃើញ និងកត់ត្រា។ យើងបាននិងកំពុងធ្វើការជាមួយរាជរដ្ឋាភិបាលកម្ពុជា និងដៃគូក្នុងស្រុក ដើម្បីពង្រឹងការការពារតំបន់ទេសភាពទាំងនេះ ដោយអាទិភាពទីមួយគឺផ្តោតលើការគ្រប់គ្រង និងការប្រើប្រាស់ប្រកបដោយចីរភាព។

អង្គការសត្វព្រៃ និងរុក្ខជាតិ បាននិងកំពុងធ្វើការជាមួយដៃគូក្នុងស្រុកដើម្បីអភិរក្សតំបន់ទេសភាពភ្នំថ្មកំបោរនៅក្នុងប្រទេសកម្ពុជា។ ថ្មីៗនេះ យើងក៏បានចេញផ្សាយនូវគោលការណ៍ណែនាំសម្រាប់ការអភិវឌ្ឍ និងការគ្រប់គ្រងល្អាងភ្នំប្រកបដោយចីរភាព។ គោលការណ៍ណែនាំនេះរួមបញ្ចូលទាំងការអនុវត្តល្អៗស្របតាមស្តង់ដាអន្តរជាតិ និងសមស្របជាមួយបរិបទកម្ពុជា ដោយផ្តល់នូវវិធានការជាក់ស្តែងដើម្បីការពារបណ្តុំសត្វប្រចៀវ និងជីវៈចម្រុះដ៏កម្រនៅក្នុងរូងភ្នំ អប់រំផ្សព្វផ្សាយទាក់ទងនឹងការប្រមូលលាមកប្រចៀវក្នុងល្អាងប្រកបដោយនិរន្តរភាព និងធានាឱ្យបាននូវការអភិវឌ្ឍន៍ទេសចរណ៍ប្រកបដោយទំនួលខុសត្រូវ។

របាយការណ៍សិក្សាស្រាវជ្រាវជីវៈចម្រុះនេះផ្តោតទៅលើក្រុមប្រភេទសត្វសំខាន់ៗមានដូចជា ប្រភេទសត្វប្រចៀវ ឧរង្គសត្វ (ល្មូន) និងថលិកសត្វ (កង្កែប) ប្រភេទខ្យង សត្វឥតឆ្អឹងកងក្នុងរូង និងរួមបញ្ចូលការសិក្សាដោយម៉ាស៊ីនថតស្វ័យប្រវត្ត (ផ្តោតលើថនិកសត្វ និងប្រភេទសត្វស្លាបលើគោក)។

សកម្មភាពនេះត្រូវបានផ្តល់មូលនិធិដោយសហភាពអឺរ៉ុប (EU) ក្រោមគម្រោង Bcoming ។

## កំណត់ចំណាំសម្រាប់អ្នកសារព័ត៌មាន

*សូមចុចលើតំណភ្ជាប់ ដើម្បីទាញយករូបភាព*

## សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទង

**កញ្ញា ហែម ម៉ានីតា** មន្ត្រីទំនាក់ទំនង នៃអង្គការសត្វព្រៃ និងរុក្ខជាតិប្រចាំកម្ពុជា

**+៨៥៥ ៩៧ ៥ ៧០៣ ៧៧០**

hem.manita@fauna-flora.org

**លោកឈិន សុភា** ប្រធានការិយាល័យ នាយកដ្ឋានជីវៈចម្រុះ ក្រសួងបរិស្ថាន
**+៨៥៥ ១៧ ៨៧៧ ៣៧៧**
chhin.sophea@moe.gov.kh

ថ្ងៃចន្ទ ៥កើត ខែចេត្រ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩
រាជធានីភ្នំពេញ, ថ្ងៃទី២៣ ខែមីនា ឆ្នាំ២០២៦